ALAMEDA COUNTY
PUBLIC HEALTH DEPARTMENT

**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

**Colleen Chawla**, Director
**Kimi Watkins-Tartt**, Director

**Office of the Health Officer**
1100 San Leandro Blvd.
San Leandro, CA 94577

**Nicholas J. Moss, MD, MPH**
County Health Officer
(510) 267-8000

# *បទបញ្ជារបស់មន្ត្រីសុខាភិបាលខោនធី Alameda ដែលតម្រូវឱ្យពាក់ម៉ាស នៅទីកន្លែងសាធារណៈបិទជិតភាគច្រើន (22-02)*
## *សំណួរសួរញឹកញាប់ (FAO)*

## *<u>បទបញ្ជា</u>*

### ហេតុអ្វីបានជា ខោនធី Alameda កំណត់ឱ្យពាក់ម៉ោសនៅកន្លែងបិទជិតឡើងវិញ?
ខោនធី Alameda កំពុងមានអត្រាឆ្លង COVID-19 ក្នុងកម្រិតខ្ពស់ ឬខ្ពស់ជាងការឆ្លងរាតត្បាតលើសពេលណាៗទាំងអស់ លើកលែងតែរលកនៃការឆ្លងវីរុសប្រភេទ Omicron រដូវរងារ។ យើងក៏ដឹងដែរថា របាយការណ៍អំពីករណីនៃការឆ្លងគឺបង្ហាញតែផ្នែកខ្លះនៃការឆ្លងសរុបប៉ុណ្ណោះ ព្រោះការធ្វើតេស្តវិជ្ជមាននៅផ្ទះភាគច្រើនពុំមានបញ្ចូលក្នុងរបាយការណ៍ឡើយ ហើយអ្នកឆ្លងជាច្រើនមិនបានធ្វើតេស្តនោះទេ។ ក្នុងពេលមានរលកនៃការឆ្លងវីរុសប្រភេទ Omicron រដូវរងា យើងប៉ាន់ស្មានថា ការឆ្លង 1 ករណីក្នុងចំណោម 4 ករណីត្រូវបានរាយការណ៍ ហើយស្ថានភាពអាចនឹងករណីដែលតិចជាង 1 ករណី ក្នុងចំណោម 8 ករណី ឬតិចជាងនេះត្រូវបានរាយការណ៍នៅពេលបច្ចុប្បន្ន។ នៅពេលនេះ យើងសង្កេតឃើញមានការកើនឡើងចំនួនអ្នកផ្ទុក COVID-19 ដែលបានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសារតែរលកនៃការឆ្លងនេះ។ វិធានការពាក់ម៉ាសអាចជួយកាត់បន្ថយអត្រាឆ្លង និងបញ្ចប់រលកនេះបានកាន់តែឆាប់រហ័ស ដើម្បីទប់ស្កាត់ការចូលសម្រាកពេទ្យបន្ថែមទៀត។

### តើលក្ខខណ្ឌពាក់ម៉ាសនឹងត្រូវដកចេញនៅពេលណា?
យើងនឹងដកចេញលក្ខខណ្ឌពាក់ម៉ាស នៅពេលដែលមានការធ្លាក់ចុះជាបន្តបន្ទាប់នូវរបាយការណ៍ករណីឆ្លងប្រចាំថ្ងៃ ដូចដែលបានបង្ហាញនៅលើ [ផ្ទាំងបង្ហាញទិន្នន័យ COVID-19]។ ទិន្នន័យរបស់យើងភាគច្រើនគឺសម្រាប់រយៈពេល 7 ថ្ងៃកន្លងទៅ ហើយយើងទំនងជាមិនដកលក្ខខណ្ឌពាក់ម៉ាសនេះដោយផ្អែកតែទៅលើទិន្នន័យបឋមតែមួយមុខឡើយ លុះត្រាតែយើងមានភស្តុតាងច្បាស់លាស់ផ្សេងទៀត ដូចជាទិន្នន័យទឹកសំណល់ដែលបង្ហាញអំពីការធ្លាក់ចុះនៃការឆ្លង COVID-19។ ការឆាប់ដកចេញនូវលក្ខខណ្ឌពាក់ម៉ាសនឹងធ្វើឱ្យវិធានការនេះពុំសូវមានប្រសិទ្ធភាព។

### ហេតុអ្វីបានជាខោនធី Alameda កំណត់ឱ្យពាក់ម៉ាសឡើងវិញ?
យើងកំពុងជួបប្រទះរលកនៃការឆ្លងជំងឺ COVID-19 ដ៏អាក្រក់បំផុតដែលយើងពុំធ្លាប់ឃើញពីមុនមកនៅក្នុងរាតត្បាតនៃជំងឺនេះ។ នៅក្នុងរលកនៃរាលដាលនេះ មន្ត្រីសុខាភិបាលខោនធី Alameda បានលើកឡើងថាវិធានការពាក់ម៉ាសអាចនឹងកំណត់ឱ្យអនុវត្តឡើងវិញ ប្រសិនបើខោនធីជួបប្រទះនឹងការឆ្លងកាន់តែធ្ងន់ធ្ងរទៅៗ ដែលយើងអាចមើលឃើញតាមរយៈកំណើននៃការចូលសម្រាកមន្ទីរពេទ្យ ឬប្រសិនបើសហគមន៍ដែលរងគ្រោះខ្លាំងពីមុនកំពុងជួបប្រទះនូវបន្ទុកជំងឺមិនស្មើគ្នាម្តងទៀត។ នៅពេលនេះ ស្ថានភាពទាំងពីរនេះបានកើតឡើងនៅខោនធី Alameda។ ដោយសារមានកំណើតនៃការចូលសម្រាកពេទ្យ យើងបានអនុវត្តវិធានការដើម្បីការពារសុខភាពសាធារណៈរបស់ពលរដ្ឋខោនធី Alameda។ យើងពុំអាចមានមតិណាមួយជំនួសឱ្យយុត្តាធិការផ្សេងទៀតឡើយ ប៉ុន្តែនៅពេលមានការរាតត្បាតជំងឺ ពលរដ្ឋខោនធី Alameda បានអនុវត្តវិធានការសុខភាពសាធារណៈខ្លាំងជាងកន្លែងផ្សេងទៀតជាច្រើន ដោយជាលទ្ធផលគឺយើងបានរួចផុតពីផលប៉ះពាល់ដ៏អាក្រក់បំផុតនៃជំងឺរាតត្បាតនេះ។

### ហេតុអ្វីបានជាលក្ខខណ្ឌនេះមិនត្រូវបានកំណត់ទៅលើសាលារៀន?
ការលើកលែងសាលា K-12 ដែលកំពុងសិក្សាពីវិធានការពាក់ម៉ាសសម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សា 2021-22 អាចធ្វើឱ្យវិធានការនេះពុំសូវមានប្រសិទ្ធភាព ប៉ុន្តែការអនុវត្តការលក្ខខណ្ឌពាក់ម៉ាសថ្មីតែរយៈពេលពីរបីថ្ងៃនៅឯសាលារៀនគឺពុំមានភាពងាយស្រួលឡើយ។ ប៉ុន្តែជារឿងល្អ ដែលខណ្ឌសាលាចំនួនពាក់កណ្តាលនៅខោនធី Alameda បានបញ្ចប់ឆ្នាំសិក្សារបស់ខ្លួនមុនពេលដែលវិធានការពាក់ម៉ាសថ្មីត្រូវបានកំណត់ឱ្យអនុវត្ត ហើយការប្រើប្រាស់ម៉ាសនៅតែមានកម្រិតខ្ពស់នៅឯសាលារៀនជាច្រើន ទោះបីជាពុំមានការកំណត់លក្ខខណ្ឌនេះពីថ្នាក់រដ្ឋ ឬខោនធីក៏ដោយ។ យើងកំពុងកំណត់ឱ្យពាក់ម៉ាសសម្រាប់សាលារដូវក្តៅ និងទីកន្លែងសម្រាប់យុវជនផ្សេងទៀត ទៅតាមលទ្ធភាពដែលអាចអនុវត្តបាន។ យើងចង់ឱ្យសាលារៀន និងបុគ្គលិកសាលាមានវិធីសាស្រ្តបត់បែនចំពោះការកំណត់ឱ្យកុមារ និងក្រុមគ្រួសាររបស់ពួកគេពាក់ម៉ាស។

### តើមានការប្រើប្រាស់ទិន្នន័យអ្វីខ្លះដើម្បីធ្វើការសម្រេចចិត្តនេះ?
យើងកំពុងប្រើប្រាស់ការចូលសម្រាកពេទ្យប្រចាំថ្ងៃរបស់អ្នកផ្ទុកជំងឺ COVID-19 រួមទាំងការចូលសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ជាមូលដ្ឋានដើម្បីចេញវិធានការចម្បងសម្រាប់ទប់ស្កាត់ជំងឺធ្ងន់ធ្ងររបស់យើង។ នេះគឺជា

វិធានការដូចគ្នាដែលយើងបានប្រើប្រាស់នៅក្នុងពេលមានការរាតត្បាតជំងឺ ហើយវិធានការនេះមានផ្សព្វផ្សាយនៅលើ ផ្ទាំងព័ត៌មានរបស់យើង ដោយមានការយឺតយ៉ាវមួយថ្ងៃ។ បច្ចុប្បន្ន មានមនុស្សចំនួន 124 នាក់កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅក្នុងខោនធី ដែលកើនឡើងពី 97 នាក់ (កើនឡើង 28%) នៅថ្ងៃទី 31 ខែឧសភា នៅពេលដែលយើងសម្រេចចិត្តឱ្យបន្តអនុវត្តនូវវិធានការនេះ។ ការចូលសម្រាកនៅមន្ទីរពេទ្យដោយសារជំងឺ COVID-19 បានកើនឡើង 190% ចាប់តាំងពីដើមខែឧសភា។ យើងក៏កំពុងតាមដានការចូលសម្រាកពេទ្យ និងការប្រែប្រួលជាមធ្យមប្រចាំថ្ងៃនៃ COVID-19 ដែលបានកើនឡើងពី 30 ទៅដល់ 50 ករណី ចាប់ពីថ្ងៃទី27 ខែឧសភា ដល់ថ្ងៃទី01 ខែមិថុនា។ យើងប្រើប្រាស់ករណីដែលរាយការណ៍អំពី COVID-19 តាមកាលបរិច្ឆេទនៃហេតុការណ៍កើតឡើង (ជាទូទៅ គឺកាលបរិច្ឆេទនៃការចាប់ផ្ដើមរោគសញ្ញា ឬការធ្វើតេស្តមន្ទីរពិសោធន៍) ដើម្បីតាមដាននៃការឆ្លង។

**តើភាពមិនស្មើគ្នានៃជំងឺ COVID-19 និងសមធម៌សុខភាព មានឥទ្ធិពលអ្វីខ្លះទៅលើការសម្រេចចិត្តនេះ?**
នៅក្នុងរយៈពេលនៃការរាតត្បាតជំងឺ សហគមន៍ពណ៌សម្បុរចម្រុះប្រាក់ចំណូលទាបបានទទួលរងនូវផលប៉ះពាល់ដ៏អាក្រក់បំផុតនៃការឆ្លងជំងឺ ការចូលសម្រាកពេទ្យ និងការស្លាប់។ យើងបានលើកឡើងជាសាធារណ: នៅពេលកើតមាននូវរលករដូវរងារ ថា ការកើតឡើងម្ដងទៀតនៃភាពមិនស្មើគ្នានៃជំងឺ COVID-19 នៅក្នុងសង្កាត់ និងក្រុមដែលរងគ្រោះខ្លាំងពីមុន នឹងក្លាយជាចំណុចដែលត្រូវពិចារណាសម្រាប់ការកំណត់ឱ្យពាក់ម៉ាសថ្មី ជាពិសេសប្រសិនបើយើងសង្កេតឃើញថា ស្ថានភាពជំងឺកាន់តែធ្ងន់ធ្ងរទៅៗ។ ការការពារសហគមន៍ដែលជួបការលំបាកបំផុត គឺជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្រ COVID-19 របស់យើងនៅខោនធី Alameda ។

កាលពីដំបូង រលករដូវរងារនេះមានលំនាំទៅតាមគំរូផ្សេងមួយទៀត ដោយមានអត្រាករណីឆ្លងទាបនៅក្នុងចំណោមក្រុមទាំងនេះដែលធ្លាប់រងគ្រោះខ្លាំងពីមុនមក ដោយមានអត្រាចូលសម្រាកពេទ្យសរុបទាប។ ទោះបីយ៉ាងណា គំរូនោះកំពុងមានការប្រែប្រួល ហើយទិន្នន័យបឋមចុងក្រោយបំផុតបង្ហាញថា ពលរដ្ឋអាមេរិកឡាទីន (Latinos) កំពុងមានអត្រាឆ្លងខ្ពស់បំផុតប្រចាំសប្ដាហ៍ជាថ្មីម្ដងទៀត គឺចំនួន 17% ខ្ពស់ជាងក្រុមដែលមានករណីឆ្លងខ្ពស់បន្ទាប់។ នៅពេលនេះយើងមិនទាន់ដឹងអំពីលក្ខណៈប្រជាសាស្ត្ររបស់អ្នកជំងឺដែលចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅឡើយទេ ដោយសារករណីទាំងនេះត្រូវបានរាយការណ៍ដោយមានការយឺតយ៉ាវ។

**ហេតុអ្វីបានជាពុំមានការកំណត់ចំណុចចាប់ផ្តើមជាក់លាក់ដើម្បីដាក់ឱ្យអនុវត្ត ឬដកចេញនូវលក្ខខណ្ឌនេះ?**
យើងដឹងអំពីមូលហេតុដែលពលរដ្ឋចង់ឱ្យមានការកំណត់ចំណុចចាប់ផ្តើមជាក់លាក់សម្រាប់វិធានការដែលធ្វើឱ្យមានការដាក់ចេញនូវវិធានការផ្សេងៗ ដូចជាការកំណត់ឱ្យពាក់ម៉ាសនេះជាដើម។ ទោះបីចំណុចចាប់ផ្តើមអាចជួយឱ្យពលរដ្ឋដឹងពីវិធានការដែលនឹងត្រូវអនុវត្តយ៉ាងណាក្តី ប៉ុន្តែយើងត្រូវគិតគូរពីវិធានការផ្សេងៗជាច្រើន ដែលក្នុងនោះរួមមាន ការចូលសម្រាកពេទ្យ អត្រាឆ្លង និងថាតើករណីទាំងនេះមានការប្រែប្រួលឆាប់រហ័សកម្រិតណា នៅពេលដែលយើងធ្វើសកម្មភាព។ លក្ខណៈប្រែប្រួលជាប់ជានិច្ចនៃជំងឺ COVID-19 និងមធ្យោបាយរបស់យើងក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺនេះ ធ្វើឱ្យមានការលំបាកក្នុងការបង្កើតចំណុចចាប់ផ្តើមជាមុនដែលអាចថ្លឹងថ្លែងអំពីកត្តាទាំងនេះឱ្យបានសមស្រប។

យោងតាមបទពិសោធន៍របស់យើង សូម្បីតែចំណុចចាប់ផ្តើមដែលត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្នក៏ដោយក៏ទាមទារឱ្យមានការវាយតម្លៃឡើងវិញជាប្រចាំដែរ។ នៅពេលយើងបានកំណត់ចំណុចចាប់ផ្តើម យើងនឹងមានការលំបាកខ្លាំងក្នុងការផ្លាស់ប្តូរយុទ្ធសាស្ត្រ ទោះបីជាស្ថានភាពមានលក្ខណៈអំណោយផលក៏ដោយ។ ការកំណត់បែបនេះអាចបណ្តាលឱ្យមានការដាក់ចេញវិធានការរឹតបន្តឹងឆាប់រហ័សពេក ឬទុកចោលយូរពេក។ ដោយសារមូលហេតុនេះហើយទើបយើងពុំបានកំណត់ចំណុចចាប់ផ្តើមទេ។ តែផ្ទុយមកវិញ ចាប់តាំងពីរលកនៃការឆ្លងនេះបានចាប់ផ្តើម យើងបាននិយាយថា ការកើនឡើងនូវការចូលសម្រាកពេទ្យ និងភាពខុសគ្នាដែលកើតឡើងម្តងទៀត គឺជាលក្ខខណ្ឌដែលយើងត្រូវកំណត់ឱ្យពាក់ម៉ាសសាជាថ្មី។

## ***<u>ម៉ាស និងការកំណត់ឱ្យពាក់ម៉ាស</u>***

**តើការកំណត់ឱ្យពាក់ម៉ាសពិតជាអាចទប់ស្កាត់ការឆ្លងដែរឬទេ?**
ត្រូវហើយ ការកំណត់ឱ្យពាក់ម៉ាសពិតជាអាចទប់ស្កាត់ឆ្លងជំងឺបាន។ ការកំណត់ឱ្យពាក់ម៉ាសកម្រិតខោនធីមានឥទ្ធិពលធ្វើឱ្យស្ថានភាពរលកជំងឺ COVID-19 កាន់តែឆាប់ធូរស្រាល ហើយខោនធី Alameda បានប្រើប្រាស់វិធានការពាក់ម៉ាសដោយជោគជ័យដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជាស្រទាប់ ដើម្បីទប់ស្កាត់ផលប៉ះពាល់ដ៏អាក្រក់បំផុតនៃជំងឺរាតត្បាត។ COVID-19 គឺជាជំងឺផ្លូវដង្ហើមដែលឆ្លងតាមខ្យល់ ហើយម៉ាសដែលមានគុណភាពខ្ពស់ និងពាក់ជិតល្អពីលើច្រមុះ និងមាត់នៅទីកន្លែងបិទជិត ជួយកាត់បន្ថយហានិភ័យនៃការឆ្លង។ ម៉ាស KF94, KN95 ឬ N95 គឺជាម៉ាសល្អបំផុតសម្រាប់ការទប់ស្កាត់នេះ ដោយសារតែម៉ាសនេះមានតម្រងចម្រោះដែលមានគុណភាពខ្ពស់។ ទោះបី ម៉ាសមានប្រសិទ្ធភាពកាត់បន្ថយការឆ្លងជំងឺ COVID-19 ក្នុងចំណោមក្រុមមនុស្សនៅទីកន្លែងបិទជិតយ៉ាងណាក្តី ប៉ុន្តែមេរោគ COVID-19 នៅតែអាចរីករាលដាលទោះបីជាមានការកំណត់ឱ្យពាក់ម៉ាសក៏ដោយ ជាពិសេសនៅទីកន្លែងឯកជន ឬទីកន្លែងដែលមនុស្សត្រូវដោះម៉ាសចេញ ឧទាហរណ៍ ដោះម៉ាសដើម្បីទទួលអាហារ ឬផឹកទឹក។ ទោះបីយ៉ាងណា ប្រសិនបើយើងអនុវត្តការពាក់ម៉ាសនៅទីកន្លែងកាន់តែច្រើន នោះយើងនឹងអាចកាត់បន្ថយការឆ្លងរាលដាលមេរោគបានកាន់តែច្រើន។

**តើការកំណត់ឱ្យពាក់ម៉ាសអាចមានប្រសិទ្ធភាពនៅខោនធី Alameda ដែរឬទេ?**

ALAMEDA COUNTY
PUBLIC HEALTH DEPARTMENT

**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

**Colleen Chawla**, Director
**Kimi Watkins-Tartt**, Director

**Office of the Health Officer**
1100 San Leandro Blvd.
San Leandro, CA 94577

**Nicholas J. Moss, MD, MPH**
County Health Officer
(510) 267-8000

ពិតជាមានប្រសិទ្ធភាព។ ពលរដ្ឋរបស់យើងបានពាក់ម៉ាសក្នុងអត្រាមួយខ្ពស់ជាងទីកន្លែងផ្សេងទៀតនៅអំឡុងពេលរាតត្បាតជំងឺកន្លងមក ដោយអត្រាពាក់ម៉ាសមានចំនួនរហូតដល់ 94% ដែលការប្រើប្រាស់នេះមានការរាយការណ៍ដោយខ្លួនឯងនៅក្នុងពេលកើតមានរលកវីរុសប្រភេទ Omicron នៅក្នុងទិន្នន័យស្ទង់មតិតាមអ៊ិនធឺណិត។ យើងកំពុងស្នើឱ្យពលរដ្ឋ ខោនធី Alameda ពាក់ម៉ាសសាជាថ្មីម្ដងទៀត ដើម្បីជួយការពារខ្លួន និងការពារគ្នាទៅវិញទៅមក។ បន្ទាប់ពីរលកវីរុសប្រភេទ Omicron បានធ្លាក់ចុះ និងមុនពេលដាក់ឱ្យអនុវត្តវិធានការចុងក្រោយនេះ ការប្រើប្រាស់ម៉ាសនៅតែមានកម្រិតខ្ពស់នៅខោនធី Alameda ដែលមានចំនួន 60-65% នៅក្នុងការស្ទង់មតិដូចគ្នា ហើយវិធានការចុងក្រោយនេះនឹងជួយបង្កើនការប្រើប្រាស់ម៉ាសម្ដងទៀតដើម្បីកាត់បន្ថយការរីករាលដាលជំងឺ COVID-19។

### ហេតុអ្វីបានជាកុមារត្រូវពាក់ម៉ាស?

កុមារអាចឆ្លងជំងឺ COVID-19 ហើយអាចចម្លងមេរោគនេះទៅអ្នកដទៃបាន។ ការលើកលែងពលរដ្ឋរាប់ម៉ឺននាក់របស់យើងដែលជាកុមារពីលក្ខខណ្ឌពាក់ម៉ាសនេះនឹងរារាំងមិនឱ្យវិធានការនេះអាចសម្រេចលទ្ធផលដែលចង់បាន។ បណ្ឌិតសភាកុមារអាមេរិក នៅតែលើកទឹកចិត្តឱ្យមានការពាក់ម៉ាសនៅក្នុងចំណោមកុមារអាយុលើសពី 2 ឆ្នាំដើម្បីការពារ COVID-19 នៅពេលដែលការឆ្លងក្នុងសហគមន៍មានកម្រិតខ្ពស់។ ជាងនេះទៅទៀត វិធានការពាក់ម៉ាសសម្រាប់កុមារគឺ "អនុវត្តទៅតាមលទ្ធភាពដែលអាចអនុវត្តបាន" ដែលមានន័យថា ការពាក់ម៉ាសម្ដងម្កាលរបស់កុមារនៅទីកន្លែងបិទជិតគឺអាចអនុញ្ញាតបានយោងតាមបទបញ្ជានេះ។ យើងគ្រាន់តែស្នើឱ្យគ្រូបង្រៀន បុគ្គលិក និងអ្នកគ្រប់គ្រង ធ្វើការអប់រំសិស្ស និងក្រុមគ្រួសារអំពីវិធានការនេះ និងសូមលើកទឹកចិត្តឱ្យសិស្សពាក់ម៉ាស ប៉ុន្តែមិនត្រូវអនុវត្តដោយបង្ខំចំពោះអ្នកដែលមិនអាច ឬមិនចង់អនុវត្តវិធានការនេះឡើយ។ ទំនួលខុសត្រូវទាំងនេះបានធ្វើឱ្យមានសម្ពាធខ្លាំងទៅលើបុគ្គលិកផ្នែកអប់រំ ហើយនឹងធ្វើឱ្យប៉ះពាល់ទៅដល់គោលដៅរបស់យើងក្នុងបន្តឱ្យកុមារសិក្សានៅក្នុងថ្នាក់។

## *ស្ថានភាពជំងឺរាតត្បាត*

### តើករណីឆ្លងដែលត្រូវបានរាយការណ៍នៅតំបន់ Bay មានស្ថានភាពយ៉ាងដូចម្ដេច?

សម្រាប់ខោនធី Alameda ករណីឆ្លងដែលបានរាយការណ៍ចាប់ពីថ្ងៃទី31 ខែឧសភា ថ្ងៃទី01 ខែមិថុនា និងថ្ងៃទី 02 ខែមិថុនា គឺសុទ្ធតែជាករណីឆ្លងសរុបខ្ពស់បំផុតប្រចាំថ្ងៃដែលយើងបានឃើញក្នុងរលករដូវរងារនេះ។ ទិន្នន័យទាំងនេះគឺជាទិន្នន័យបឋមនៅឡើយ ហើយចំនួនសរុបអាចខ្ពស់ជាងនេះនៅពេលធ្វើការសរុបចុងក្រោយ។ យុត្តាធិការតំបន់ Bay មួយចំនួនបានឃើញករណីឆ្លងកើនឡើងមុនខោនធី Alameda ទៅទៀត ហើយនៅពេលនេះប្រហែលជាកំពុងមានរបាយការណ៍ករណីរីករាលដាល ប៉ុន្តែមិនទាន់មានសញ្ញានៃការឆ្លងខ្ពស់នៅខោនធី Alameda នៅឡើយទេ។

### តើពុំមានពលរដ្ឋដែលចូលសម្រាកពេទ្យដោយសារជំងឺផ្សេង ហើយត្រូវបានតេស្តវិជ្ជមាន COVID ទេឬ?

ចំនួនអ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យរបស់យើងរួមមាន អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយសាររោគសញ្ញាធ្ងន់ធ្ងរនៃជំងឺ COVID-19 ក៏ដូចជាអ្នកដែលចូលសម្រាកព្យាបាលដោយសារបញ្ហាផ្សេងទៀត ប៉ុន្តែបានធ្វើតេស្តវិជ្ជមាន COVID-19។ ស្ថានភាពនេះពិតជាកើតឡើងមែននៅក្នុងរលកនៃការឆ្លងនីមួយៗ ហើយយើងពុំមានតួលេខប៉ាន់ស្មានតាមពេលវេលាជាក់ស្តែងនៃទិន្នន័យនីមួយៗទេ។ ទោះបីយ៉ាងណា ការកើនឡើងនៃការចូលសម្រាកពេទ្យបង្ហាញអំពីការកើនឡើងនៃបុគ្គលទាំងពីរប្រភេទ ដែលអាចនាំឱ្យមានបន្ទុកកាន់តែធ្ងន់ធ្ងរពាក់ព័ន្ធនឹងប្រព័ន្ធថែទាំសុខភាពរបស់យើង។ ជាការកត់សម្គាល់ អ្នកដែលមានជំងឺ COVID-19 ដែលសម្រាកនៅមន្ទីរពេទ្យដោយសារមូលហេតុផ្សេងទៀត គឺជាការដាក់សម្ពាធ និងហានិភ័យបន្ថែមចំពោះប្រព័ន្ធថែទាំសុខភាព ព្រោះវាអាចចម្លងមេរោគ COVID-19 ទៅដល់មនុស្សដែលមានហានិភ័យខ្ពស់ និងត្រូវការការថែទាំកម្រិតខ្ពស់។

**តើយើងពុំមានការប្រឈមទាបជាងមុនចំពោះការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដោយសារមានពលរដ្ឋជាច្រើនបានចាក់វ៉ាក់សាំង និងចាក់ដូសជំរុញ ទេឬ?**
ពលរដ្ឋជាច្រើនមានហានិភ័យទាបពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដោយសារតែបានចាក់វ៉ាក់សាំង និងចាក់ដូសជំរុញ ភាពស៊ាំពីការឆ្លងជំងឺកន្លងមក និងការទទួលបានការព្យាបាល COVID-19 ក៏ដូចជាដោយសារស្ថានភាពសុខភាពរបស់ពួកគេម្នាក់ៗផងដែរ។ ទោះបីយ៉ាងណា ពលរដ្ឋមួយចំនួននៅតែងាយរងគ្រោះ បើទោះជាបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ ហើយការចូលសម្រាកពេទ្យ ហើយករណីស្លាប់នាពេលថ្មីៗនេះរបស់យើង គឺជាបុគ្គលដែលបានចាក់វ៉ាក់សាំង និងមិនបានចាក់វ៉ាក់សាំង។ នៅពេលដែល COVID-19 ដ៏ច្រើននេះកំពុងចរាចរនៅក្នុងសហគមន៍របស់យើង ចំនួនករណីជំងឺធ្ងន់ធ្ងរនឹងមានការកើនឡើង បើទោះបីជាយើងមានស្រទាប់ការពារជាច្រើនសម្រាប់ពលរដ្ឋរបស់យើងក៏ដោយ។

**តើយើងទាំងអស់គ្នាពុំធ្លាប់ឆ្លងជំងឺ COVID-19 ទេឬ? តើយើងទាំងអស់គ្នាសុទ្ធតែត្រូវឆ្លងជំងឺនេះឬ?**
មានការប៉ាន់ស្មានថា 56% នៃពលរដ្ឋកាលីហ្វ័រញ៉ាបានឆ្លងជំងឺ COVID-19 នៅត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ2022។ បុគ្គលជាច្រើនពុំទាន់បានឆ្លង COVID-19 នៅមុនកើតមានរលកនេះទេ ហេតុដូច្នេះហើយទើបយើងភាគច្រើនបានទទួលព័ត៌មានអំពីករណីឆ្លងជាច្រើន នៅក្នុងបណ្តាញរបស់យើងនៅពេលនេះ។ ប្រសិនបើគ្មានវ៉ាក់សាំងដែលបញ្ឈប់ការចម្លងទេ នោះយើងទាំងអស់គ្នាទំនងជាបានឆ្លងជំងឺ COVID-19 ជាច្រើនដងនៅក្នុងមួយជីវិតរបស់យើង ហើយប្រសិនបើមិនទាំងអស់គ្នា ក៏យើងភាគច្រើនប្រហែលជានឹងឆ្លងជំងឺនេះ ជាច្រើនដង។ ទោះបីយ៉ាងណា នៅពេលដែលយើងឃើញមានការកើនឡើងករណីជំងឺធ្ងន់ធ្ងរនៅក្នុងសហគមន៍របស់យើង គឺមានន័យថា មានវិធានការជាច្រើនទៀតដែលយើងអាចអនុវត្តដើម្បីព្យាយាមទប់ស្កាត់ផលប៉ះពាល់ដ៏អាក្រក់បំផុតនៃ COVID-19 និងផ្តល់នូវឱកាសជាច្រើនទៀតនៅក្នុងការបញ្ចៀសលទ្ធផលដ៏អាក្រក់បំផុត។

យើងមិនត្រូវចាត់ទុកថា ការចូលសម្រាកពេទ្យ និងការស្លាប់ គឺជាករណីដែលមិនអាចជៀសរួចឡើយ។ ក្នុងរដូវដែលមានករណីផ្តាសាយដ៏អាក្រក់ឆ្នាំ2017-18 មានមនុស្សចំនួន 1690 នាក់បានស្លាប់ដោយសារជំងឺគ្រុនក្តៅនៅទូទាំងរដ្ឋ។ ចាប់តាំងពីថ្ងៃទី01 ខែមករា ឆ្នាំ2022 ទោះបីជាមានការផ្តល់វ៉ាក់សាំង ការចាក់ដូសជំរុញ និងការព្យាបាលយ៉ាងទូលំទូលាយក៏ដោយ ក៏មានពលរដ្ឋកាលីហ្វ័រញ៉ាចំនួន 15,024 នាក់បានស្លាប់ដោយសារជំងឺ COVID-19។